# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជាជាមួយអដ្ឋិធាតុរបស់សន្ត លូវីស និងសន្តី ហ្សេលី ម៉ាតាំង
# ភ្នំពេញថ្មី ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៩
# យកព្រះជាម្ចាស់ជាអាទិភាព

**អត្ថបទទី១៖ ព្រះប្រាជ្ញាញាណ ៩,១៣-១៨**

ប្រសិនបើព្រះអង្គមិនបានប្រោសប្រទានព្រះប្រាជ្ញាញាណ ហើយមិនបានចាត់ព្រះវិញ្ញាណដ៏វិសុទ្ធរបស់ព្រះអង្គ ពីស្ថានដ៏ខ្ពស់មកទេនោះ គ្មាននរណាអាចស្គាល់បំណងរបស់ព្រះអង្គបានឡើយ។ ប្រាញ ៩,១៧

**អត្ថបទទី២៖ ភីលេម៉ូន ១,៩-១០.១២-១៧**

ខ្ញុំមានបំណងចង់ទុកគាត់ឲ្យនៅជាមួយខ្ញុំដែរ ដើម្បីឲ្យនៅបម្រើខ្ញុំជំនួសលោកប្អូន ក្នុងពេលខ្ញុំជាប់ឃុំឃាំង ព្រោះតែដំណឹងល្អនេះ។ ភល ១,១៣

**ដំណឹងល្អ៖ លូកា ១៤,២៥-៣៣**

ក្នុងចំណោមអ្នករាល់គ្នា បើអ្នកណាមិនលះបង់អ្វីៗទាំងអស់ដែលខ្លួនមានទេ អ្នកនោះមិនអាចធ្វើជាសាវ័ក*របស់ខ្ញុំបានឡើយ។ លក ១៤,៣

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ ជាថ្ងៃដែលធាតុសន្ត លូវីស និងសន្តី ហ្សេលី ចេញដំណើរទៅបាត់ដំបង ក្រោយមកទៅកំពង់ចាម។ ជាឱកាសមួយដើម្បីអរព្រះគុណព្រះជាម្ចាស់ គម្ពីរដែលយើងស្ដាប់ថ្ងៃនេះណែនាំឲ្យយើងជ្រើសរើសព្រះជាម្ចាស់ "**បើអ្នកណាចង់មកតាមខ្ញុំ តែមិនស្រឡាញ់ខ្ញុំខ្លាំងជាងឪពុកម្ដាយ ប្រពន្ធកូនបងប្អូនប្រុសស្រីនិងជីវិតរបស់ខ្លួនទេ អ្នកនោះមិនអាចធ្វើជាសាវ័ករបស់ខ្ញុំបានឡើយ**" យើងស្ដាប់មួយទៀត "**អ្នកណាមិនលីឈើឆ្កាង**" យើងស្ដាប់មួយទៀត "**អ្នកណាដែលមិនអង្គុយរិះគិតមុនដើរតាមខ្ញុំ**" និងចុងក្រោយ "**បើអ្នកណាមិនលះបង់អ្វីៗទាំងអស់ដែលខ្លួនមានទេ អ្នកនោះមិនអាចធ្វើជាសាវ័ករបស់ខ្ញុំបានឡើយ**" នេះដូចជាកំពូលនៃជីវិតរបស់សន្ត លូវីស និងសន្តី ហ្សេលី ដែលបានអនុវត្តន៍អត្ថបទគម្ពីរដំណឹងល្អដែលយើងបានស្ដាប់ថ្ងៃនេះ។ អស់មួយជីវិតរបស់គាត់ ពីដើមរៀងមករហូតដល់ទទួលមរណភាព គេបានយកចិត្តទុកដាក់ជ្រើសរើសព្រះជាម្ចាស់ជាអាទិភាព។ ជីវិតរបស់គាត់ គឺជ្រើសរើសព្រះជាម្ចាស់ជាអាទិភាព ពីក្មេងរហូតដល់ទទួលមរណភាពគេបានទុកព្រះជាម្ចាស់ជាអាទិភាព។ ដូច្នេះ អាចទៅជាសំណួរសម្រាប់យើងដែរ **នៅក្នុងជីវិតរបស់យើងប្រចាំ នៅក្នុងសង្គមរបស់យើងប្រចាំ តើយើងទុកព្រះជាម្ចាស់ជាអាទិភាពឬទេ?**

នៅក្នុងពីរសប្ដាហ៍កន្លងមក ខ្ញុំសរសេរនិងអានច្រើនអំពីជីវិតរបស់ ហ្សេលី និង លីវីស ខ្ញុំមានអារម្មណ៍ថាខ្ញុំបានចូលនៅក្នុងជីវិតគ្រួសារនេះ។ គ្រួសារនេះ រកឃើញសុភមង្គលម្យ៉ាងប៉ុន្តែ

ឆ្លងទុក្ខលំបាកយ៉ាងច្រើនដែរ កូនដែលស្លាប់ ប្រពន្ធដែលស្លាប់មុនអាយុទុកឲ្យមានកុមារកំព្រារ បញ្ហានានាដែលគេមានដូចគ្រួសារទាំងអស់ ដើម្បីអប់រំណែនាំកូន ជីវិតរបស់គេដែលត្រូវការចេញពីទីក្រុងដែលគេនៅពីដើមទៅទីក្រុងមួយទៀត ដោយសារបញ្ហារកស៊ីនិងបញ្ហាជីវិតប្រចាំ។ ណែនាំឲ្យខ្ញុំឃើញគ្រួសារនេះ រកឃើញសេចក្ដីសុខដោយសារគេយល់ថាព្រះជាម្ចាស់សំខាន់ ព្រះជាម្ចាស់ជាអាទិភាព ព្រះជាម្ចាស់ណែនាំឲ្យគេរកឃើញសេចក្ដីសុខ។ មិនមែនថា គេអធិដ្ឋានពីព្រឹកដល់យប់ មិនមែនមានន័យថាគេបានបង្កើតអារាមមួយនៅក្នុងផ្ទះរបស់គេ ប៉ុន្តែនៅក្នុងជីវិតគេពេលគេភ្ញាក់ពីដេកគេអធិដ្ឋាន ពេលគេចូលដេកគេអធិដ្ឋាន ពីមួយថ្ងៃទៅមួយថ្ងៃគេនឹកឃើញព្រះជាម្ចាស់រហូត។ ដូច្នេះ នៅក្នុងខ្លួនគេគេរកឃើញសេចក្ដីសុខដោយសារជីវិតរបស់គេមិនមែនតែនៅមើលការរកស៊ី បញ្ហាដែលគេមាន ឬការឈឺចាប់ដែលគេមាននៅក្នុងជីវិត គេយល់ថាការរកស៊ីផង ឈឺចាប់ផង ជម្ងឺផង កូនស្លាប់ផង ទុក្ខលំបាកក៏នៅមាន ប៉ុន្តែគ្រប់ទុក្ខលំបាកគេផ្ញើទៅព្រះជាម្ចាស់អស់ហើយ។ ដូច្នេះ នេះគឺជារបៀបដែលគេបានជ្រើសរើសព្រះជាម្ចាស់ជាអាទិភាព **"បើអ្នកចង់មកតាមខ្ញុំ តែមិនស្រឡាញ់ខ្ញុំខ្លាំងជាងឪពុកម្ដាយ ប្រពន្ធកូន បងប្អូនប្រុសស្រី និងជីវិតរបស់ខ្លួនទេអ្នកនោះពុំអាចធ្វើជាសាវ័កខ្ញុំបានឡើយ"**។

**"អ្នកណាមិនលីឈើឆ្កាងរបស់ខ្លួនមកតាមខ្ញុំទេ អ្នកនោះពុំអាចធ្វើជាសាវ័កខ្ញុំបានដែរ"** ឈើឆ្កាងនៅក្នុងគ្រួសារនេះមិនខ្វះទេ ជាពិសេស ហ្សីលី ពេលគាត់ដល់ថ្ងៃចុងក្រោយនៃជីវិតរបស់គាត់ ដោយសារគាត់មានជំងឺមហារីកសុដន់ដែលមិនអាចព្យបាលបាន គាត់បានត្រៀមខ្លួនត្រៀមខ្លួនមិនមែនតែដើម្បីស្លាប់ ប៉ុន្តែត្រៀមខ្លួនចូលនៅក្នុងព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់។ នៅពេលគាត់បង្ហាញអំពីទឹកចិត្តរបស់គាត់ មិនដែលមានអ្វីថាគាត់ស្អប់ព្រះជាម្ចាស់ គាត់ខឹងព្រះជាម្ចាស់ គាត់យល់ថាអ្វីៗទាំងអស់មកព្រះជាម្ចាស់។ ដូច្នេះ ខ្ញុំទទួលដោយដឹងថាខ្ញុំត្រូវតែទុកចិត្តលើព្រះជាម្ចាស់ ជំនឿមានន័យថាផ្ញើជីវិតទាំងស្រុងលើព្រះជាម្ចាស់ ខ្ញុំត្រូវការទុកចិត្តលើព្រះជាម្ចាស់ ដោយសារព្រះជាម្ចាស់ណែនាំឲ្យខ្ញុំរស់នៅ នៅក្នុងសេចក្ដីសុខមួយម្យ៉ាង។ តាមពិតពីដើមរៀងមក គាត់ថាខ្ញុំចង់ធ្វើជាសន្តីមួយរូប ខ្ញុំចង់ស្គាល់ស្ថានបរមសុខពិតប្រាកដមែន។ ហេតុនេះហើយ ពេលគាត់ធ្វើដំណើរទៅដល់សេចក្ដីស្លាប់ គាត់មិនភ័យខ្លាចទេនៅពេលគាត់ទៅទីក្រុងលួដ៍ដើម្បីទូលអង្វរព្រះនាងម៉ារី ដើម្បីទូលអង្វរព្រះជាម្ចាស់ឲ្យព្យាបាលគាត់ គាត់ដឹងថាព្យាបាលមិនបាន ប៉ុន្តែនៅលួដ៍មានការអស្ចារ្យមួយកើតឡើង គឺគាត់បានយល់ថាខ្ញុំត្រូវតែទុកចិត្តលើព្រះជាម្ចាស់ ឥលូវនេះដល់ពេលវេលាខ្ញុំលីឈើឆ្កាងខ្ញុំ ខ្ញុំលះបង់ចោលអ្វីៗទាំងអស់ដើម្បីផ្ញើជីវិតរបស់ខ្ញុំ គ្រួសាររបស់ខ្ញុំ ប្ដីរបស់ខ្ញុំ កូនៗរបស់ខ្ញុំទៅលើព្រះជាម្ចាស់។ ខ្ញុំដឹងថាព្រះនាងម៉ារី នឹងយកចិត្តទុកដាក់ថែរក្សាគ្រួសារខ្ញុំ ព្រះជាម្ចាស់នឹងយកចិត្តទុកដាក់ថែរក្សាគ្រួសារខ្ញុំ។ នៅពេល

នោះ គាត់បានរកឃើញសេចក្ដីសុខនៅក្នុងដួងចិត្តរបស់គាត់ ដោយសារជីវិតរបស់គាត់ឥលូវនេះ លែងមានអ្វីទាំងអស់ប៉ុន្តែដឹងថាព្រះជាម្ចាស់នៅ។

ដូច្នេះ អត្ថបទគម្ពីរដែលយើងស្ដាប់ថ្ងៃនេះមានន័យដល់កំពូលណាស់ នៅពេលយើងមើលឃើញជីវិតរបស់ លូវីស និង ហ្សីលី។ នៅពេលយើងស្ដាប់ព្រះបន្ទូលរបស់ព្រះយេស៊ូ យើងយល់សម្រាប់ជីវិតយើងដែរ មានពេលវេលាមួយដែលយើងត្រូវការយល់ថា នៅសល់តែព្រះជាម្ចាស់ ប៉ុន្តែនៅសល់តែព្រះជាម្ចាស់បានលុះត្រាតែយើងយកព្រះជាម្ចាស់ជាអាទិភាព។ បើពីមួយថ្ងៃទៅមួយថ្ងៃយើងអត់ដែលរវីរវល់ជាមួយព្រះជាម្ចាស់ អត់ដែលរវីរវល់ជាមួយនឹងព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដល់ពេលវេលាដែលជីវិតរបស់យើងដូចជាធ្លាក់នៅក្នុងការអស់សង្ឃឹម ធ្លាក់នៅក្នុងការអស់កម្លាំងកាយកម្លាំងចិត្ត ធ្លាក់នៅក្នុងសុខភាពមិនល្អ ធ្លាក់នៅក្នុងបញ្ហានានាដែលយើងជួប យើងរកឃើញកម្លាំងពីណាមក ប្រសិនបើជីវិតរបស់យើងអត់ដែលមានទំនាក់ទំនងជាមួយព្រះជាម្ចាស់ និងអត់ដែលជាប់ជាមួយព្រះជាម្ចាស់។ សង្គមបច្ចុប្បន្ននេះ មិនណែនាំឲ្យយើងនឹកឃើញព្រះជាម្ចាស់ជាព្រះរបស់យើង សង្គមរបស់យើងសព្វថ្ងៃណែនាំឲ្យយើងទទួលស្គាល់ថាទ្រព្យសម្បត្តិជាអ្វីដែលសំខានជាងគេ អាត្មានិយមជាអ្វីដែលសំខាន់ជាងគេ ចិត្តចង្អៀតចង្អល់ជាអ្វីដែលសំខាន់ជាងគេ។ ប៉ុន្តែ នៅពេលយើងយកព្រះជាម្ចាស់ជាអាទិភាព នៅពេលយើងចូលនៅក្នុងទុក្ខលំបាកនៃជីវិត យើងដឹងថាយើងមានទីពឹងមួយយ៉ាងពិសេស ដែលណែនាំឲ្យជីវិតរបស់យើងអាចទៅមុខទៀត។

សន្ត ហ្វ្រង់ស្វ័រឌីសាល ធ្លាប់និយាយថា "**នៅពេលខ្ញុំធ្វើអំពើល្អមួយ នៅពេលខ្ញុំយកចិត្តទុកដាក់លះបង់ចោលអ្វីតែមួយតូច នៅពេលខ្ញុំកំពុងរងទុក្ខលំបាកមានអត្ថន័យច្រើនជាង នៅពេលខ្ញុំកំពុងធ្វើអំពើល្អ ពេលជីវិតខ្ញុំមានសេចក្ដីសុខនិងអំណរសប្បាយ**"។ អត្ថន័យ គឺនៅពេលខ្ញុំលះបង់ចោល នៅពេលខ្ញុំជួយគេតិចតួច នៅពេលខ្ញុំយកចិត្តទុកដាក់នឹងអ្នកក្រីក្រតិចតួច អំឡុងពេលខ្ញុំកំពុងពិបាកនៅក្នុងជីវិតខ្ញុំ មានអត្ថន័យ មានតម្លៃខ្លាំងជាងនៅពេលខ្ញុំធ្វើអំពើល្អអំឡុងពេលខ្ញុំមានអំណរសប្បាយនិងសេចក្ដីសុខ។ ប៉ុន្តែ ដើម្បីធ្វើនេះបានយើងត្រូវតែភ្ជាប់ជាមួយព្រះជាម្ចាស់ពីមួយថ្ងៃទៅមួយថ្ងៃ។ ហ្សីលី ធ្វើអំពើល្អនៅលើផែនដីយើងដូចសន្តីតេរេសានៃព្រះកុមារយេស៊ូ សន្តីតេរេសានៃព្រះកុមារយេស៊ូនៅមុនពេលគាត់ស្លាប់ គាត់បានសរសេរថា "**ខ្ញុំទៅស្ថានបរមសុខ ខ្ញុំបានធ្វើអំពើល្អនៅលើផែនដីនេះ នៅពេលខ្ញុំឡើងស្ថានលើខ្ញុំនឹងយកចិត្តទុកដាក់ចំពោះបងប្អូនដែលនៅស្ថានកណ្ដាល ដើម្បីមានសេចក្ដីសុខនិងជីវិតតទៅទៀត**"។ នៅពេលយើងប្រកាសជំនឿរបស់យើង យើងថាយើងជឿលើសហភាពជនដ៏វិសុទ្ធ មានន័យថាជនដ៏វិសុទ្ធគឺសន្តសន្តីនៅស្ថានបរមសុខហើយ កំពុងសហការជាមួយយើងនៅលើផែនដីនេះដើម្បីឲ្យយើងទៅមុខ។ ដូច្នេះ

នៅពេលយើងអធិដ្ឋានតាមរយៈសន្តសន្តី យើងមិនខុសឆ្គងទេយើងទទួលកម្លាំងមួយយ៉ាងពិសេស ដើម្បីឲ្យយើងធ្វើដំណើរតទៅទៀត ដើម្បីរកឃើញកម្លាំងនៅក្នុងជីវិតរបស់យើង។

សាលឌីហ្វូហ្គូល ធ្លាប់និយាយថា "**ឱព្រះបិតាអើយ! ខ្ញុំលះបង់ចោលអ្វីៗទាំងអស់ផ្ញើទៅលើព្រះអង្គ សូមព្រះអង្គធ្វើទៅតាមចិត្តអំពីជីវិតរបស់ខ្ញុំ អ្វីៗទាំងអស់ដែលព្រះអង្គធ្វើខ្ញុំនឹងអរព្រះគុណព្រះជាម្ចាស់ ខ្ញុំត្រៀមខ្លួនដើម្បីទទួលអ្វីៗទាំងអស់ពីព្រះអង្គ ដោយសារខ្ញុំដឹងថាព្រះអង្គជាព្រះបិតារបស់ខ្ញុំពិតមែន**"។ ជារៀងរាល់ថ្ងៃ ពេលខ្ញុំភ្ញាក់ពីដេកខ្ញុំផ្ញើជីវិតរបស់ខ្ញុំទៅលើព្រះបិតា ទោះបីជាថ្ងៃនេះមានអ្វីកើតឡើង មានសេចក្តីសុខ មានការឈ្លោះគ្នា មានអំណរសប្បាយ មានការច្រណែន មានបញ្ហានេះ មានបញ្ហានោះ មានសេចក្តីសង្ឃឹម ខ្ញុំផ្ញើទៅព្រះជាម្ចាស់ទាំងអស់ដោយដឹងថាព្រះជាម្ចាស់មានព្រះហឫទ័យស្រឡាញ់ខ្ញុំ អ្វីៗទាំងអស់ដែលព្រះអង្គសម្រេចចិត្តខ្ញុំទទួលដោយសារព្រះជាម្ចាស់ជាព្រះបិតារបស់ខ្ញុំ។

ថ្ងៃនេះ យើងអរព្រះគុណព្រះជាម្ចាស់ដែលបានជ្រើសរើសយើង ទៅជាបុត្រាបុត្រីរបស់ព្រះអង្គ យើងទូលអង្វរព្រះអង្គតាមរយៈសន្ត លូវីស និងសន្តី ហ្សេលី ឲ្យយើងចេះលះបង់ចោលដើម្បីយកព្រះជាម្ចាស់ជាអាទិភាព ពេលយើងយកព្រះជាម្ចាស់ជាអាទិភាពយើងជឿថាជីវិតរបស់យើង រកឃើញសុភមង្គលដ៏ពិតប្រាកដ។ អាម៉ែន៕